*មីងលីសនិងពូជឿន*

ក្លិនផ្កាសាយភាយមកពីក្រៅ.....

ទិដ្ឋភាពដែលទទួលបាន វាប្រៀបបីដូចជារដូវរំហើយឈានមកដល់។

ការផ្លាស់ប្តូរជាទៀងទាត់នៃធម្មជាតិតាមរដូវកាលតែងតែមានសភាពដ៏ស្រស់បំព្រងម្យ៉ាងៗ។

កាលពីនៅមានឪពុកម្តាយរបស់ខ្ញុំ នាមជាកូនតូចម្នាក់ដូចជាខ្ញុំនេះ ក៏តែងតែបានដើរកម្សាន្តយ៉ាងសប្បាយជាពិសេសនៅពេលបុណ្យចូលឆ្នាំសាកល។

ទោះបីយើងមិនមែនជាគ្រិស្តសាសនិកតែខ្ញុំមានឈ្មោះដូចជាពួកបារាំង។

ម្តាយខ្ញុំដាក់ឈ្មោះខ្ញុំថាសាឪណា។

ជាការពិត ខានបានដើរកម្សាន្តក្រៅផ្ទះជាច្រើនឆ្នាំមកហើយ។

មិនមែនថាខ្ញុំមិនចូលចិត្តរបៀបដើរលេងតាមរដូវទេ ប៉ុន្តែខ្ញុំត្រូវជីវិតបង្ខំឱ្យធ្វើខ្លួនជាមនុស្សម្នាក់ផ្សេងទៀតដែលមិនមែនខ្ញុំ ។

ដែលក្លែងខ្លួនជាអ្វីម្យ៉ាងយូរៗក៏មានអារម្មណ៍ថា ខ្លួនឯងលែងជាខ្លួនដូចពីមុនទៀតដែរទេ? ខ្ញុំពេលនេះហើយ គឺបែបនេះ។

ហើយទោះបីខ្ញុំមានពេលច្រើនសញ្ជឹងគិតរឿងពីមុនយ៉ាងណាក៏ដោយ ភាគច្រើនខ្ញុំចំណាយពេលនឹករឿងអតីតកាលណាដែលមានម្តាយខ្ញុំនិងឪពុករបស់ខ្ញុំប៉ុណ្ណោះ។ អ្នកមានគុណទាំងទ្វេផ្តើមមានតម្លៃខ្លាំង ត្រឹមពេលខ្ញុំត្រូវបាត់បង់ពួកគាត់....គឺបាត់បង់គំហុកពេក ឈឺណាស់! ការឈឺចាប់មួយនេះ បានធ្វើឱ្យខ្ញុំក្លាយជាបែបនេះ។

ឪពុកខ្ញុំគឺជាគ្រូបង្រៀន ចំណែកម្តាយខ្ញុំគឺជាមេផ្ទះ ប៉ុន្តែគាត់តែងតែចំណាយពេលទៅធ្វើជាអ្នកអ៊ុតខោអាវ នៅតាមកន្លែងដែលមានភ្ញៀវបរទេសរស់នៅ ការនេះដើម្បីរកប្រាក់បន្ថែមផ្គត់ផ្គង់គ្រួសារ។

ជាការពិតណាស់ខ្ញុំអផ្សុកដែលរស់នៅគ្មានប្អូន បន្ថែមទាំងគ្មានបង ប៉ុន្តែខ្ញុំអាចមានលុយមករៀនទាំងភាសាបារាំងនិងអង់គ្លេសបន្ថែមពីលើការរៀននៅសាលារដ្ឋព្រោះបន្ទុកពុកម្តាយខ្ញុំផ្ទុកមកលើកូនទោលតែម្នាក់នេះ។

រាល់ថ្ងៃអាទិត្យ ប៉ានិងម៉ាក់ខ្ញុំតែងតែនាំខ្ញុំទៅលេងចាស់ទុំ មាធំរបស់ខ្ញុំ(អ៊ំស្រី ត្រូវជាបងច្បងរបស់ប៉ា)នៅស្រុកកៀនស្វាយ និងលោកយាយ។

«ឱ ធម្មជាតិអើយ បង្កើតខ្ញុំហើយ ម្តេចឡើយមកប្រល័យ....»

ជាបទចម្រៀងដែលឮត្រឹមមួយកំណាត់នេះ តែឮមករាល់តែថ្ងៃ។

ជាសំឡេងមនុស្សស្រី មិនមែនបុរសច្រៀងទេ ដ្បិតតែជាបទដើមពីអធិរាជសំឡេងមាសលោកតា ស៊ីន ស៊ីសាមុត។ គាត់ឈ្មោះមីងលីសជាមនុស្សមិនចងចាំ គេហៅថាជាអ្នកឈឺធ្ងន់វិបល្លាសដល់ថ្នាក់មិនអាចនៅស្រុកបាន ត្រូវមកបង្ខាំងព្យាបាល។

គាត់ច្រៀងបទនេះ ដដែលជាដដែលចាប់តាំងពីខ្ញុំចូលនៅព្យាបាលនៅមន្ទីរល្វាស្វាយនេះ តែមិនធ្លាប់ឃើញគាត់ និយាយស្តីរកអ្នកណាទាំងអស់។

ខ្ញុំអាណិតគាត់ណាស់ ឮថាគាត់ខ្លួនឯងដំបូងមិនមានវិបល្លាសទេ លុះដល់យប់មួយ ដែលមានស្នូរជើងមនុស្សដើរចូលមកក្រោមផ្ទះ គាត់ចុះទៅ មិនស្មានថាជាកូនគាត់ចុះមកដែរ ឃើញស្រមោលស្ទង់ៗ គាត់ក៏បាញ់ចំកូនស្រីខ្លួនឯងអាយុ១៧ឆ្នាំ ។ ក្រោយកូនទោលរបស់គាត់ស្លាប់ក្រោមគ្រាប់កាំភ្លើងនោះ ម្តាយក៏សន្សឹមៗ ក្លាយជាវិកលព្រោះវិប្បដិសារៈមកទល់បច្ចុប្បន្ន។ ប្តីគាត់ឈ្មោះដឿន បានចូលមកនៅទីនេះដែរ បានតួនាទីជាអ្នកយាម និងបាននៅក្បែរមើលប្រពន្ធផង។

មន្ទីរល្វាស្វាយនេះ ជាមណ្ឌលសម្រាប់មនុស្សដែលមានការគិតមិនប្រក្រតី មានឫកពាវិកល ហើយខ្ញុំត្រូវបានគេបញ្ជូនមកកន្លែងនេះដែរ ក៏ព្រោះថា ជាញឹកញយខ្ញុំធ្វើសកម្មភាពដូចជា អ្នកដែលមានអាការៈរងជំងឺវិកល។ រឿងនេះកើតមាននៅក្រោយប៉ុន្មានឆ្នាំ ដែលឪពុកម្តាយខ្ញុំបានត្រូវរងគ្រោះថ្នាក់ចរាចរណ៍ស្លាប់។

....ឮបទចម្រៀងរបស់មីងលីស  ខ្ញុំជូតទឹកភ្នែក ប៉ុន្តែខ្ញុំញញឹម។

ជីវិតឯកោបែបនេះ ពិតជាឈឺចាប់ណាស់។ ការញញឹមរបស់ខ្ញុំ អ្នកមិនយល់ទេថា ចិត្តនេះកំពុងឈឺចាប់កម្រិតណា។ ខ្ញុំរស់ត្រដរមក ព្រោះត្រចៀកនៅតែឮសំឡេងរបស់ម្តាយខ្ញុំ គាត់តែងតែប្រាប់ខ្ញុំថា គាត់ទៅអ៊ុតខោអាវឱ្យគេបានលុយតិចប៉ុនណាក៏គាត់តស៊ូ ព្រោះគាត់ស្រឡាញ់ខ្ញុំ ចង់ឃើញខ្ញុំមានអនាគត បានរៀនភាសាបរទេស បានចេះដឹង បានធ្វើការធំដុំ មិនហត់បោកអ៊ុតខោអាវដូចគាត់។

ដូច្នេះខ្ញុំតែងតែតស៊ូ.....កូនតស៊ូជានិច្ចម៉ាក់!

ខ្ញុំមានផែនការអ្វីម្យ៉ាង ដែលគ្មាននរណាដឹងទេ សូម្បីតែអ្នកដែលកំពុងអាននេះ ក៏ខ្ញុំអត់ប្រាប់ដែរ។

*អេតមីននីន និង មីងទេពី*

«ឪណា អី ឪណា!»

ជាសំឡេងរបស់អេតមីននៅមណ្ឌលល្វាស្វាយ។ អេតមីននេះឈ្មោះបង នីន។ គាត់តែងតែស្រែកហៅខ្ញុំគំហុកៗបែបនេះ ព្រោះខ្ញុំធ្វើស្ពឹក ធ្វើមិនឮ។

«អ្នកផ្ទះយករបស់របរមកឱ្យ!»

ខ្ញុំអង្គុយធ្វើស្ងៀមដូចរាល់ដង ចាំទាល់តែគាត់មកកន្ត្រាក់ដៃខ្ញុំ នាំខ្ញុំចេញទៅ។

យើងដើរកាត់រនាំងទ្វារជាច្រើន ទម្រាំមកដល់បន្ទប់តូចមួយ។

ពេលគាត់បើកទ្វារ ខ្ញុំមានអារម្មណ៍ថា ចង់តែក្អួតចង្អោរនិងចប់ដង្ហើម ព្រោះខ្ញុំឃើញមីងទេពី ជាប្អូនស្រីបង្កើតរបស់ប៉ាមកដល់ជាមួយនិងស្បោងធំមួយ។

ខ្ញុំញញឹមហើយស្រែកហៅគាត់មីងៗ។

មីងទេពីសម្លឹងខ្ញុំពីលើដល់ក្រោមដោយទឹកមុខជិនឆ្អន់។

ខ្ញុំដឹងច្បាស់ គាត់ឃើញភ្នែកខ្ញុំរូងខ្មៅ ដៃខ្ញុំមានច្រវាក់ ហើយខ្ញុំជា«មនុស្សឆ្កួត» ។

ឃើញមនុស្សចិត្តមិនស្មោះម្នាក់នេះ  ខ្ញុំក៏នឹកឃើញថ្ងៃមួយយូរហើយ កាលដែលគាត់បានឈ្លោះគ្នា វាយតប់ជាមួយប្ដីគាត់ ត្រូវប្ដីរបួសបែកមុខមាត់ ហើយប្ដីត្រូវចូលគុកបាត់ គាត់មកតាមសុំឪពុកខ្ញុំស្នាក់នៅជាមួយ។

ប្រហែលដឹងមារយាទគាត់ថាមិនល្អ លាក់ពុតត្បុតច្រើន ឪពុកខ្ញុំជេរស្ដីគាត់ មិនចង់ឱ្យនៅទេ ព្រោះគាត់ជាមនុស្សញៀនលេងបៀប៉ោឡែ ប៉ុន្តែម្ដាយខ្ញុំអាណិតពេក គាត់ក៏យល់ព្រមឱ្យឱកាសកែខ្លួនម្ដងទៀត។

ម្ដាយខ្ញុំនាំទៅរកការងារបោកគក់ជាមួយ តែមីងទេពីនេះមិនដែលធ្វើការពេញដៃជើងទេ រវល់ប្រឹងតែងខ្លួន ច្រវាត់រកប្ដីបរទេស។

កាលនោះខ្ញុំទើបតែអាយុប្រាំពីរឬប្រាំបីឆ្នាំ តែខ្ញុំចងចាំគ្រប់យ៉ាងបានច្បាស់។ ឥឡូវនេះទៀត ខ្ញុំអត់ទ្រាំហៅមនុស្សចង្រៃនេះថាមីង ព្រោះខ្ញុំចង់ឱ្យគាត់យល់ថា ខ្ញុំមិនដឹងអី និងឈឺឆ្កួតដូចដែលគាត់ចង់បាន។ មីងខ្ញុំហុចស្បោងមកឱ្យ៖

«នេះរបស់ឯងក្មួយកម្សត់!»

ពាក្យនិយាយរបស់មីងទេពី ហៅខ្ញុំថាក្មួយកម្សត់ពិតជាគួរឱ្យចង់ឆ្កួតបំណាច់តែព្ទ តែខ្ញុំរឹតប្រឹងញញឹមស្រស់ ហើយភ្នែកសម្លឹងរកអីវ៉ាន់ដែលគាត់ផ្ញើ។

ពេលដែលខ្ញុំធ្វើដូចជាសប្បាយចិត្តចំពោះអីវ៉ាន់នោះ ឈ្មោះនីនជាអេតមីន បានទទួលលុយពីរបីសន្លឹកពីមីងទេពី។ អេតមីននេះ ប្រាកដជាបានទទួលសំណូករបស់មីងទេពីដាក់ឱ្យប្រចាំការតាមដានពីខ្ញុំ និងរាយការណ៍ថាខ្ញុំត្រូវបន្តទទួលការព្យាបាល ដើម្បីរារាំងមិនឱ្យខ្ញុំបានចាកចេញពីទីនេះ។

អេតមីននីនម្នាក់នេះ គាត់តែងតែលបមើលខ្ញុំពេលដែលខ្ញុំអង្គុយបែរខ្នងនិយាយជាមួយជញ្ជាំងម្នាក់ឯងដូចជាមនុស្សឆ្កួតមែនទែន ហើយគាត់ក៏ងាកទៅទូរស័ព្ទទៅរាយការណ៍ប្រាប់មីងទេពី។

ពេលនេះទៀតសោត ហ៊ានទទួលស្រោមសំបុត្រនិងលុយនៅមុខខ្ញុំ ពួកគេទុកថាខ្ញុំឆ្កួតមែនទែនហើយ?

«កុំឱ្យក្មួយខ្ញុំបានជួបអ្នកណាផ្សេង!»

មីងទេពីផ្តាំផ្ញើ។

លុយដូចជាក្រាស់គួរសម ធ្វើឱ្យអេតមីនញញឹមបិទមាត់មិនជិតទេ។

«កុំភ័យបង!»

អេតមីននីនញាក់ភ្នែកដាក់មីងខ្ញុំជាសញ្ញាថា ខ្ញុំគ្មានថ្ងៃចេញពីមណ្ឌលល្ហាស្វាយបាននោះទេ ព្រោះមិនមានរបាយការណ៍ធូរស្បើយ។

ខ្ញុំគ្មានប៉ាម៉ាក់ មានតែមីងម្នាក់គ្រាន់ពឹង តែប៉ះចំមីងចិត្តចោរ បានប្តីជនជាតិតណ្ហា សេពគប់មូលគំនិតគ្នាប្រុងលេបដីផ្ទះប៉ាម៉ាក់ខ្ញុំ ក៏រៀបគម្រោងធ្វើបាបខ្ញុំ បញ្ជូនខ្ញុំមកកន្លែងនេះ គិតមិនឱ្យខ្ញុំបានចេញវិញដាច់ខាត។

ខ្ញុំធ្វើជាបង្ហាញភាពសប្បាយរីករាយនៅក្នុងកែវភ្នែក ពេលឃើញនំនែក សំឡីអនាម័យនិងរបស់ប្រើប្រាស់ពេញក្នុងថង់ រួចពេលគេនិយាយគ្នាត្រូវហើយ មីងកំណាចក្រឡេកមករកខ្ញុំឃើញខ្ញុំសើចដាក់គាត់ធ្វើដូចជាមនុស្សឆ្កួតដែលគាត់ចង់ឃើញ គាត់ក៏បានចិត្តលូកដៃមកស្ទាបប៉ះថ្ពាល់ខ្ញុំ។

មីងទេពីគ្មានពាក្យអ្វីថ្មីទេ។

«ក្មេងល្អ រស់នៅទីនេះស្តាប់បង្គាប់គេទៅ!»

រួចហើយគាត់ក៏ចាកចេញទៅ។ ខ្ញុំធ្វើជាស្ទុះឱបគាត់ ប៉ុន្តែគាត់មិនឱ្យខ្ញុំឱបនោះទេ ព្រោះគាត់មិនមានចេតនាល្អជាមួយខ្ញុំ។

«តោះយើង ត្រឡប់ចូលទៅវិញ!»

បងនីនអេតមីនធ្វើជាចិត្តល្អ ជួយកាន់ថង់ឱ្យខ្ញុំ តាមពិតទៅដល់ក្នុងកំបាំងជញ្ជាំង គាត់ដកប្រមូលយកអស់របស់ណាៗដែលគាត់ចង់បាន ។ ខ្ញុំមិនដែលបានទទួលរបស់ក្នុងស្បោងនោះទេ ភាគច្រើនគេលួចយកទាំងអស់ៗ ទុកឱ្យខ្ញុំតែបន្តិចបន្តួចដូចជា នំស្បោងក្មេងៗស្រួយៗ តម្លៃប្រាំរយមួយពាន់រៀលអីហ្នឹង ក្រៅពីនោះថ្នាំដុសធ្មេញ សាប៊ូកក់សក់អ្វីផ្សេងៗ គឺអេតមីននេះទទួលយកគ្រប់យ៉ាង។

ទាំងនេះព្រោះគេគិតថាខ្ញុំឆ្កួត មិនដឹង មិនយល់ ថែមទាំងមិនអាចបកស្រាយប្រាប់អ្នកណាទាំងអស់ពីចរិតចង្រៃរបស់ពួកគេ។

ទោះបីយ៉ាងណាក៏ដោយ ពិភពលោកនេះមិនអាចយុត្តិធម៌ខ្លាំងដូចដែលអ្នកអានកំពុងគិតឡើយ កុំខឹង ឬឈឺចិត្តពេក ខ្ញុំមានដំណឹងល្អ....

*មីងទេននិងប៉ូលិសបង្កប់*

«នែកាទែន! ជូតតដ្ឋញាប់ៗ ជូតឱ្យឆាប់ហើយស្រូតចេញមកណ៎! កុំនៅជាមួយក្មេងហ្នឹងយូរពេក ប្រយ័ត្នវាច្របាច់កឯង!»

អេតមីននីនតែងតែសម្លុតមីងទែន ជាអ្នកបោសសម្អាតដែលមានចិត្តធម៌។

មីងទែននេះ តាមពិតត្រូវបានមិត្តម្នាក់របស់ពុកជួលឱ្យចូលមកទីនេះ តាមមើលថែខ្ញុំជាសម្ងាត់។ គ្រូបង្រៀនម្នាក់ជិតស្និទ្ធជាមួយឪពុករបស់ខ្ញុំ បានរកវិធីទាក់ទងមីងទែន ឱ្យគាត់ស្ម័គ្រចិត្តជាភ្នែកច្រមុះនៅទីនេះដើម្បីជួយខ្ញុំ។

រឿងយ៉ាងដូច្នេះ....គឺនៅថ្ងៃមួយដែលខ្ញុំបានចូលមកមន្ទីរនេះ ព្រោះតែបោកប្រាស់អីវ៉ាន់ក្នុងផ្ទះ ទាំងអ្នកជិតខាង ទាំងមិត្តភក្តិ ទាំងគ្រូរបស់ខ្ញុំយល់ថា ខ្ញុំមានជំងឺវិកលចរិតក្រោយពេលដែលបាត់បង់ឪពុកម្តាយភ្លាមៗ ទទួលយកមិនបាន ប៉ុន្តែមីងទែននេះ ខ្ញុំអត់ស្គាល់ឈ្មោះពេញរបស់គាត់ទេ ស្គាល់តែថា គាត់គឺជាមនុស្សដែលមិត្តជិតស្និទ្ធជាមួយឪពុកម្តាយខ្ញុំបានជួលឱ្យមកជួបជាសម្ងាត់ជាមួយខ្ញុំ។

ពេលមួយនិយាយយល់គ្នាដឹងថា ខ្ញុំមិនបានឆ្កួត គ្រាន់តែខ្ញុំមានបញ្ហាធ្លាក់ទឹកចិត្ត គាត់បានប្រាប់ខ្ញុំគ្រប់យ៉ាង។ គាត់ថាប៉ូលិសកំពុងសង្ស័យថា មីងទេពីនិងប្តីបរទេសចូលដៃគ្នា លេបយកដីធ្លីផ្ទះសម្បែងដែលឪពុកម្តាយខ្ញុំមានជាកម្មសិទ្ធិ។

នេះក៏ជាអ្វីមួយ ដែលប៉ាខ្ញុំសង្ស័យបានធ្លាប់និយាយជាមួយមិត្តរបស់គាត់មុនពេលត្រូវរងគ្រោះស្លាប់ គាត់ថាចេះតែមានប្រផ្នូលថា ប្អូនស្រីគាត់ក្បត់គាត់។

ដូច្នេះបានជាពូនោះបានជួបខ្ញុំជាសម្ងាត់នៅសាលា ដោយប្រាប់ខ្ញុំឱ្យប្រុងប្រយ័ត្នមិនឱ្យហូបចុកអ្វីក្នុងផ្ទះមួយរយៈសិន រួចរកមធ្យោបាយចាកចេញពីការគ្រប់គ្រងរបស់មីងទេពី។

ថ្ងៃមួយខ្ញុំធ្វើជាឡូឡាឆ្កួតវង្វេង ហើយធ្វើជាដេកសន្លប់ ទើបខ្ញុំដឹងថា មីងទេពីនិងប្រុសៗបរទេសពីរ បីនាក់តែងតែចូលមកក្នុងផ្ទះនេះសំងំនិយាយគ្នារឿងលេបយកដីធ្លីរបស់ខ្ញុំ។

ខ្ញុំក៏ប្រញាប់យករឿងនេះទូរស័ព្ទទៅប្រាប់គ្រូដែលជាមិត្តជិតដិតរបស់ប៉ា។

មែន ពេលនោះយើងក៏ចាប់ផ្តើមរៀបចំរឿងនិទានមួយឡើង ឆ្លើយតបទៅនឹងអំពើចង្រៃរបស់ពួកគេ។ មីងទែនបានឱកាសនៅតែពីរនាក់ហើយកាលណាគាត់ផ្តើមខ្សឹបខ្សៀវ៖

«ក្មួយឪណាដឹងដែរថា អេតមីនីននេះត្រូវគ្នាជាមួយនឹងទេពី ពួកគេមិនឱ្យក្មួយចេញទៅផ្ទះវិញទេ! កោតណាស់ ជាមីងបង្កើតរបស់ឯងប៉ុន្តែមានគំនិតបែបនេះ បើសិនជាឪពុកឯងនៅ ហើយឃើញអ៊ីចឹងសួរថាតើតែគាត់ត្រូវឈឺចាប់ប៉ុនណា?»

មីងបោសជូតផងខ្សឹបប្រាប់ខ្ញុំផង។

ខ្ញុំវិញផ្អែកក្បាលនឹងជញ្ជាំងងើយសម្លឹងដំបូល។ ភាគច្រើនខ្ញុំតែងតែមានពេលនិយាយរឿងសម្ងាត់នេះជាមួយមីងទែន រង់ចាំឱកាសឱ្យប៉ូលិសមានភស្តុតាងកម្ចាត់មនុស្សអាក្រក់អស់ទាំងនោះ។

តាមខ្ញុំដឹងឪពុកខ្ញុំប្រហែលជាធ្លាប់និយាយរឿងជាច្រើនដែលគាត់បានមើលឃើញអំពីប្អូនស្រីគម្រក់របស់គាត់ ប្រាប់មិត្តគាត់។

ពេលនេះ មីងទែននិងមិត្តភក្តិរបស់ប៉ា បាននឹងកំពុងធ្វើការស្និទ្ធជាមួយប៉ូលិសបង្កប់ រកភស្តុតាងធំជាងរឿងមីងទេពីស៊កលុយអេតមីនទៅទៀត គឺត្រឹមអេតមីននីនម្នាក់មិនអាចទុកខ្ញុំនៅទីនេះបានយូរទេ ពួកគេគិតថា មានអ្នកនៅពីក្រោយការក្លែងលិខិតថាខ្ញុំមិនអាចវិលទៅរៀនវិញបាន។

«កុំអស់សង្ឃឹមណាក្មួយ ប៉ូលិសបង្កប់ម្នាក់ បានមកដល់មណ្ឌលនេះ រឿងក្មួយជិតបានសម្រេចហើយ ក្មួយឪណានឹងបានទៅរៀនវិញ!»

ខ្ញុំឱនមកខ្សឹបដាក់គាត់៖

«ប៉ូលិសម្នាក់ហ្នឹង ខ្ញុំឃើញគាត់ហើយមីង! មកម្សិលមិញពេលល្ងាចញ៉ាំបាយនៅរោង! ត្រូវហើយ ពីដំបូងវិញ ស្មានតែគាត់ជាមនុស្សឆ្កួតមែន! គាត់មិនហូប គិតពីសើចនិងសម្លក់ ហើយយំ! គាត់ក្លែងបន្លំធ្វើជាមនុស្សឆ្កួត មិននិយាយ និងមិនស្តាប់យើងបានទេ!»

ប៉ូលិសបង្កប់មានវ័យចំណាស់អង្គុយម្នាក់ឯងនៅសួនច្រងុំក១។

ពួកគេខ្លះនិយាយថាគាត់ឈ្មោះតាសាក់ ខ្លះថាតារក្ស មានតែខ្ញុំទេដឹងថាគាត់ជាប៉ូលិស។

គាត់ប៉ិនសម្តែងណាស់ ពេញមួយថ្ងៃមក មិននិយាយរកអ្នកណា ព្រឹកមិញពូអ្នកយាម ដែលឈ្មោះដឿន មានករិយាវិកលគឺមីងលីស ធ្វើជាទៅអង្គុយនិយាយលេងជាមួយគាត់ និយាយបែកអូរហូរស្ទឹងរឿងអ៊ុយក្រែននិងរុស្សីក៏គាត់មិនឆ្លើយតបជាមួយ ធ្វើដូចជា Mute សំឡេងនិងថ្លង់ក្រដាសត្រចៀកអ៊ីចឹងដែរ។

«បើរកឃើញការពិតគេបិទទីនេះទេមីង?»

ខ្ញុំសួរមីងទែន។

មីងធ្វើភ្នែកក្រឡេកក្រឡាប់ហើយខ្សឹប៖

«ប្រាកដណាស់! ឪណាចាំរឿងពូសោភណ្ឌទេ!»

ខ្ញុំធ្លាក់ទឹកមុខហើយងក់ក្បាល។

រឿងពូសោភណម្នាក់នេះ ពិតជាមានសាច់រឿងកម្សត់ខ្លាំងណាស់។

តាមខ្ញុំដឹង គាត់គឺជាកូនប្រុសរបស់អ្នករកស៊ីម្នាក់ធូរធារនៅខេត្តកំពង់ចាម ប៉ុន្តែដោយសារតែគាត់មានដីចម្ការធំ ហើយគាត់គឺជាកូនប្រុសតែមួយគត់ដែលនឹងទទួលមរតក ដូច្នេះហើយបងៗស្រីៗរបស់គាត់ដែលមានប្ដីហើយ បានរួមដៃគ្នារកគ្រប់វិធីធ្វើឱ្យគាត់មានជំងឺ ហើយបង្កើតនូវសកម្មភាពចលាចលធ្វើឱ្យគាត់ចេញកាយវិការប្លែកៗជាច្រើននឹងរួមដៃជាមួយនឹងពេទ្យខ្លះមកបញ្ជាក់ថា គាត់ត្រូវតែមកសម្រាកនៅមន្ទីរពេទ្យវិកលល្វាស្វាយនេះ ទាំងដែលគាត់គ្មានជម្រើសអ្វីក្រៅមកសម្រាកនៅទីនេះ។

ពេលគាត់ទាមទារថាគាត់មិនបានឈឺ គ្មានអ្នកណាព្រមជឿគាត់ទាល់តែសោះ។

នៅផ្ទះគាត់មានកើតហេតុឆេះឃ្លាំង ក៏គេទម្លាក់កំហុសថាគាត់ជាអ្នកដុត។

មានអ្នកឈឺល្មមៗខ្លះដែលគេមកនៅមុន ធ្លាប់តំណាលថា ថ្ងៃមួយ ពូសោភណ្ឌបានលួចរត់ចេញពីកន្លែងនេះព្រោះលបឮប្រធានមន្ទីរនិយាយទូរស័ព្ទជាមួយបងស្រីនិងបងថ្លៃគាត់ អំពីរឿងមិនចង់ឱ្យគាត់ចេញពីទីនេះជារៀងរហូត នឹងអាលបានលេបយកដីចម្ការរបស់គាត់។

ដោយសាររត់មិនបានសម្រេច ដូច្នេះពួកខាងមន្ទីរពេទ្យក៏ចាប់គាត់ឃុំវិញ។

អ្នកផ្សេងថា មិនដឹងគេធ្វើទារុណកម្មគាត់របៀបណាទេ ថ្ងៃស្អែកឡើងក៏មានព័ត៌មានថាគាត់លោតពីលើដំបូលផ្ទះស្លាប់ ដូច្នេះហើយមីងទែន តែងតែប្រាប់ខ្ញុំឱ្យប្រុងប្រយ័ត្នចំពោះមន្ទីរមួយនេះ ប្រធានមន្ទីរល្វាស្វាយកំពុងស្ថិតក្នុងការស៊ើបអង្កេតជាសម្ងាត់ ដោយសារប៉ូលិសទទួលបានបណ្ដឹង និងពិនិត្យរកឃើញករណីគួរសង្ស័យជាច្រើននៅកន្លែងនេះ តែគេនៅមិនទាន់អាចមានឯកសារយោងគ្រប់គ្រាន់នឹងអាលបានចោទប្ដឹងតាមផ្លូវច្បាប់នៅឡើយ។